**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
គណៈកម្មាធិការលទ្ធកម្ម(គល-PC)
លេខៈ០១៤........សជណ/គល/១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៩ ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ទីស្តីការគណៈរដ្ឋមន្ត្រី សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ទីស្តីការគណៈរដ្ឋមន្ត្រី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០១៩ ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ២៨.... ខែ មីនា........ ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ ( មូរស័ព្ទទាក់ទងលេខ ០២៣ ២១២៤៧៩ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង១០:០០...ថ្ងៃទី.១០.......ខែ.មេសា......ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅសាលប្រជុំលេខ 1-16A វេលាម៉ោង.១០:០០....... ថ្ងៃទី.១០....... ខែមេសា.....ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហ.៧រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម** ( **គល**-PC)

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ

**អង្គភាពលទ្ធកម្ម**
**គ.រ.ម** ទំព័រ1